# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការជំរុញការនាំចេញកសិផល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការជំរុញការនាំចេញកសិផល ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- | ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | ប្រធាន |
| ២- | ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៤- | ឯកឧត្តម **សុន គន្ធរ** អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |

៥- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- សិក្សាអំពីតម្រូវការនៅលើទីផ្សារក្នុងប្រទេស ដើម្បីតម្រង់ទិសកសិករក្នុងការផលិត ឱ្យស្របតាមសេចក្តីត្រូវការរបស់ទីផ្សារ
- សិក្សាអំពីបែបបទ និងលក្ខខណ្ឌនានារបស់ទីផ្សារអន្តរជាតិ សម្រាប់បម្រើឱ្យការនាំចេញផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម
- ស្វែងរកទីផ្សារក្នុងស្រុក និងទីផ្សារក្រៅប្រទេស សម្រាប់នាំចេញផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម
- ទាក់ទាញ ជំរុញ និងលើកទឹកចិត្តដល់ការវិនិយោគទុនក្នុងស្រុក និងបរទេស លើដំណាំកសិកម្ម និងកសិ-ឧស្សាហកម្ម
- រៀបចំផែនការផ្គត់ផ្គង់ទឹក ពិនិត្យលទ្ធភាពផ្តល់ទុន ណែនាំអំពីពូជដំណាំ ការប្រើប្រាស់ជីបច្ចេកទេសដាំដុះ និងកំណត់តំបន់ដាំដុះ
- ជ្រើសរើសទីកន្លែង និងការរៀបចំអនុវត្តសាកល្បងផលិតដំណាំកសិកម្ម និងកសិ-ឧស្សាហកម្ម នៅទីកន្លែងណាមួយសមស្រប
- បង្កលក្ខណៈឱ្យបានសមស្រប ដើម្បីឱ្យមានការដាំដុះនៅក្នុងភូមិសាស្ត្រដែលមានប្រព័ន្ធធារាសាស្ត្រ និងឱ្យស្របតាមសេចក្តីត្រូវការរបស់ទីផ្សារ
- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈកម្មការ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការជំរុញការនាំចេញកសិផល ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងមានលេខាធិការដ្ឋានជាជំនួយការងារ នៅទីស្តីការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីជន ដែលមានចែងនៅក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៥ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ